# ខ្លឹមសារសង្ខេបសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើពាក្យសុំរបស់នួន ជា ប្តឹងជិតចិត្តចៅក្រម Marcel Lemonde

**002/29-10-2009-ECCC/PTC(04) ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០**

**<u>ពាក្យគន្លឹះ</u>**៖បណ្តឹងជិតចិត្ត, គោលការណ៍សន្មតថាមិនលម្អៀង, បន្ទុកភស្តុតាង

**ក**. នួន ជា (**នជ**) បានដាក់ញត្តិមកអង្គបុរេជំនុំជម្រះ (Pre-Trial Chamber: PTC) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) ប្តឹងជិតចិត្តសហចៅក្រមអន្តរជាតិចៅក្រម Marcel Lemonde (ML)។ បណ្តឹងនេះ ផ្អែកលើមូលដ្ឋានជាច្រើន ដូចជាខ្លឹមសារនៃសេចក្តីសម្រេច ដែលទំនងជាមានលក្ខណៈលម្អៀងប្រឆាំង **នជ** និងជាពិសេស សំដីរបស់អតីតប្រធានក្រុមអ្នកវិភាគរបស់ ML ឈ្មោះ Bastin (B) ដែលអះអាងថា មានការណែនាំឲ្យស៊ើបអង្កេតប្រមូលតែភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ (**នជ**)។ បណ្តឹងនេះស្នើឲ្យ ML ដកខ្លួនពីការស៊ើបអង្កេតនាពេលខាងមុខ។

**ខ**. អនុលោមតាមនីតិវិធី PTC ត្រូវពិនិត្យជាដំបូងថាតើអាចទទួលញត្តិនេះមកពិចារណាបានឬទេ? តាមវិធាន៣៤(៣)នៃវិធានផ្ទៃក្នុងរបស់ អវតក **នជ** មានកាតព្វកិច្ចដាក់ភស្តុតាងនិងត្រូវធ្វើញត្តិឲ្យបានឆាប់ ក្រោយពីបានដឹងអំពីមូលដ្ឋានសម្រាប់ដាក់ញត្តិ(*ភាគីដែលធ្វើបណ្តឹងជិតចិត្ត ត្រូវ<u>បង្ហាញឲ្យច្បាស់លាស់អំពីមូលហេតុ</u>នៃបណ្តឹង និងត្រូវមានភស្តុតាងបញ្ជាក់ផងដែរ ។ ពាក្យបណ្តឹងត្រូវធ្វើឡើងឲ្យ<u>បានឆាប់បំផុតតាម</u>ដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ*) ។

**គ**. ចៅក្រម ML អះអាងថា **នជ** បានដាក់បណ្តឹងមកយឺត។ PTC រកឃើញថា **នជ** បានលឺព័ត៌មានពីសារព័ត៌មានអំពីរឿងនេះយូរហើយ និងបានសុំការបំភ្លឺពី ML ដែលការបំភ្លឺនេះមិនតម្រូវដោយច្បាប់ឬវិធានទេ។ ព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយ មិនមែនជាភស្តុតាងគួរឲ្យទុកចិត្តបានទេ។ ដូចនេះ បណ្តឹងរបស់ **នជ** ដាក់ក្រោយមកក្នុងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ (មុនពេលចេញដីកាដំណោះស្រាយ) មិនយឺតទេ។ PTC អាចទទួលយកមកពិនិត្យបាន (កថា.១៣)។

**ឃ**. ពាក់ព័ន្ធអង្គសេចក្តី PTC បានយោងដល់<u>សេចក្តីសម្រេចលើបណ្តឹងជិតចៅក្រម នៃ ថុល</u> ដែលទាមទារនូវកម្រិតភស្តុតាងខ្ពស់គាំទ្របណ្តឹងជិតចិត្ត៖*អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា“ចំនុចចាប់ផ្តើមនៃការសម្រេចលើការជំទាស់អំពីភាពលម្អៀង] គឺថា“មានការសន្មតទុកជាមុនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម””ការសន្មតនេះ កើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់*

*ចៅក្រម និងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងរបស់គាត់[ ...] " និងដាក់បន្ទុកដ៏ធ្ងន់ចំពោះភាគីដែលធ្វើបណ្ដឹងជំទាស់ក្នុងការដកចេញនូវការសន្មតទុកជាមុននេះ"*។[1]

អនុលោមតាមទ្រឹស្ដី ដែលសន្មតថាគ្មានភាពលម្អៀង (presumption of impartiality) ទាញពីបទប្បញ្ញត្តិច្បាប់ ឬក្រមសីលធម៌ពាក់ព័ន្ធមួយចំនួនដូចជា (មាត្រា១០ថ្មីនៃច្បាប់ស្ដីពី អវតក)។ ឯកសារបង្ហាញថា មិនមានភស្ដុតាងច្រើននិងផ្ទាល់ជាលាយលក្ខណ៍អក្សរទេ។ មានតែអត្ថបទរបស់ Bastin (អ្វីដែលបានលឺក្នុងកិច្ចប្រជុំជាមួយចៅក្រម ML ក្នុងខែសីហា ឆ្នាំ២០០៩) បង្កើតដោយមេធាវីរបស់ **នជ** និងមិនមានសាក្សីណាគាំទ្រ, សំដីនោះ មិនមែនជាការណែនាំរបស់ចៅក្រម ML គ្រាន់តែជាការនិយាយក្នុងកិច្ចប្រជុំជាភាសាបរទេស (ចៅក្រម ML ជាជនជាតិបារាំង) ហើយចៅក្រម ML អះអាងថា គាត់មិនបានដឹងថានិយាយដូចនេះទេ។ ផ្អែកតាមមូលហេតុនេះ PTC អះអាងថា មិនមានភស្ដុតាងរឹងមាំ ដូចនេះសម្រេចបដិសេធនូវបណ្ដឹង។

**<u>កំណត់សំគាល់</u>**៖ **ក.** PTC បានអះអាងថា ភាពលម្អៀងមានពីរប្រភេទ៖ លម្អៀងពិត (actual bias) ដូចជាក្នុងករណីចៅក្រមជាភាគីនៃសំណុំរឿង ដែលខ្លួនវិនិច្ឆ័យ) និង លម្អៀង (apprehended bias) ផ្អែកតាមភស្ដុតាង (circumstantial evidence) ដូចជាខ្លឹមសារដែលសរសេរក្នុងសេចក្ដីសម្រេចរបស់ខ្លួន។ **ខ.** PTC បានឯកភាពពិចារណាយកស្ដង់ដារមនុស្សមានហេតុផល (<u>reasonable person/observer</u>) ជាមូលដ្ឋានវាស់វែងថាតើចៅក្រមមានភាពលម្អៀងឬមិន។ **គ.** តាមខ្លឹមសារនៃសេចក្ដីសម្រេច សម្រាប់បណ្ដឹងជំទាស់ ភាគីដាក់បណ្ដឹងមាន<u>បន្ទុកដាក់ភស្ដុតាង ហើយភស្ដុតាងត្រូវមានកម្រិតខ្ពស់។</u> **ឃ.** ដើម្បីធានាអព្យាក្រឹត្យភាព ចៅក្រមស៊ើបសួរ ត្រូវបានតម្រូវឲ្យស៊ើបអង្កេតទាំងភស្ដុតាងដាក់និងដោះបន្ទុក (ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១២៧)។ **ង.** ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ បានចែងផងដែរនិងលម្អិតអំពីបណ្ដឹងជំទាស់ ក៏ប៉ុន្តែ មិនមាននិយាយអំពីបន្ទុកនិងកម្រិតនៃភស្ដុតាងទេ។ ខ្លឹមសារនៃសេចក្ដីសម្រេចនេះ អាចជួយដល់ចៅក្រមកម្ពុជា ដើម្បីពិចារណា។

**មាត្រា ៥៥៦មូលហេតុនៃការប្ដឹងជំទាស់ចៅក្រមអាសនៈ**

បណ្ដឹងជំទាស់អាចត្រូវទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈប៉ុណ្ណោះ ។

ចៅក្រមទាំងឡាយអាចត្រូវប្ដឹងជំទាស់ ដោយមូលហេតុដូចខាងក្រោមនេះ ៖

---

[1] The Pre-Trial Chamber notes that "the starting point for any determination of a claim [ of bias} is that "there is a presumption of impartiality which attaches to a Judge". "This presumption derives from their oath to office and the qualifications for their appointment {. .. ], and places a high burden on the party moving for the disqualification to displace that presumption".

- ......

- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្ដី ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ .... កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្ដី...កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឱ្យភាគីចំពោះរឿងក្ដី ឬ កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្ដីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្ដី ឬបានចូលរួមក្នុងការសម្រេចសេចក្ដីនៅសាលាដំបូងដែលបានប្ដឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្ដី ។

**មាត្រា ៥៥៧ពាក្យប្ដឹងជំទាស់ចៅក្រមអាសនៈ**

ភាគីដែលចង់ប្ដឹងជំទាស់ចៅក្រមអាសនៈណាមួយ ត្រូវតែជូនពាក្យប្ដឹងតាំងពីពេលដែលខ្លួនបានដឹងពីមូលហេតុនៃការប្ដឹងជំទាស់បើពុំដូច្នេះទេមិនអាចទទួលបានឡើយ ។ ក្នុងករណីណាក៏ដោយពាក្យប្ដឹងជំទាស់ចៅក្រមមិនអាចធ្វើបានឡើយ នៅក្រោយពេលបិទការពិភាក្សាដេញដោល ។